# ព្រះបន្ទូល



ពេញមួយសម័យកាល ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺព្រះគម្ពីរ មានឥទ្ធិពលយ៉ាងសំខាន់មកលើអរិយធម៌។ បច្ចុប្បន្ននេះ មនុស្សរាប់លាននាក់មកពីគ្រប់ជាតិសាសន៍ នៅតែបន្តទទួលបាននូវការលើកទឹកចិត្ត នៅពេលអស់សង្ឃឹម តាមរយៈការអាន និងសិក្សាព្រះគម្ពីរ។ ទាំងបុគ្គលម្នាក់ៗ និង សង្គមជាតិទាំងមូល កំពុងតែទទួលបាននូវការផ្លាស់ប្រែ នៅពេលដែលពួកគេបន្ទាបខ្លួននៅក្នុងការស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ កាលពីប៉ុន្មានឆ្នាំមុន មាននារីវ័យក្មេងដ៏ស្រស់ស្អាតម្នាក់ ទទួលបានសៀវភៅមួយក្បាលជាអំណោយ។ នាងឃើញថា សៀវភៅនោះហាក់ដូចជាសោះកក្រោះ មានពណ៌ស្រអាប់ ហើយសៀវភៅនោះ ត្រូវបានទុកចោលនៅលើទូដាក់សៀវភៅមួយ។ នៅពេលដែលនាងមានមុខមាត់នៅក្នុងសង្គម



ក៏មានគេណែនាំនាងឱ្យស្គាល់បុរសវ័យក្មេងរូបរាងស្អាតបាតម្នាក់ ឈ្មោះថា **អេក្ស ដាប់បលយូ វូដ** **(H.W. Wood)** ។

នាងបានរៀបរាប់ក្នុងកំឡុងពេលនៃការសន្ទនាមួយថា នាងមានសៀវភៅមួយក្បាលនៅផ្ទះ ដែលសរសេរដោយលោក **វូដ(Wood)**។

តាមការពិត នាងក៏បានលើកឡើងថា អ្នកនិពន្ធនោះមានឈ្មោះជាអក្សរកាត់ដូចគ្នានឹងបុរសនោះដែរ។ អ្នកកំលោះរូបនោះបានឆ្លើយទៅនាងថា គឺគាត់នឹងហើយដែលជាអ្នកដែលបានសរសេរសៀវភៅនោះ ។ នារីវ័យក្មេងនោះក៏ត្រឡប់មកផ្ទះវិញ ហើយក៏ចាប់ផ្ដើមអានសៀវភៅនោះរហូតដល់ពាក់កណ្ដាលអធ្រាត្រទើបនាងអានចប់ ។ ខណៈពេលនោះនាងកំពុងតែទទួលបាននូវការទាក់ទាញចិត្តពីអ្នកនិពន្ធ នាងក៏ចាប់ផ្ដើមឃើញថាសៀវភៅនោះជាសៀវភៅដែលគួរឱ្យចាប់អារម្មណ៍បំផុត។ បន្ទាប់ពីនោះមក នាងបានក្លាយជាអ្នកស្រី**អេច ដាប់បលយូ វូដ (H.W. Wood)**។ ការស្គាល់អ្នកនិពន្ធបានធ្វើឱ្យមានការផ្លាស់ប្ដូរទាំងស្រុង។

មិនខុសពីការស្គាល់ព្រះយេស៊ូ ជាការដែលផ្ដល់ពន្លឺថ្មីលើព្រះរាជសារព្រះគម្ពីរនោះទេ។ (ប្រភពមិនស្គាល់)

## លក្ខណៈរបស់ព្រះគម្ពីរ

*សូមបំពេញនៅចន្លោះខាងក្រោម ៖*

*១. ______________________ អេសាយ ៤០: ៨ (ម៉ាថាយ ២៤:៣៥)*

*២. ______________________ អេសាយ ៥៥:១១*

*ជនគណនា ២៣:១៩ «ព្រះទ្រង់មិនមែនជាមនុស្សដែលចេះកុហកនោះឡើយ ក៏មិនមែនជាកូនមនុស្សដែលផ្លាស់ប្ដូរគំនិតនោះដែរ។ ព្រះអង្គបានសន្យាហើយ តើទ្រង់មិនធ្វើតាមទេឬ? ព្រះអង្គបានមានព្រះបន្ទូលហើយ តើទ្រង់មិនសម្រេចតាមទេឬ?»* ចូររៀនប្រកាសព្រះបន្ទូលសន្យារបស់ ព្រះជាម្ចាស់ ប៉ុន្តែ ការធ្វើបែបនេះសូមគោរពតាមលក្ខខណ្ឌដែលបានបង្ហាញក្នុង បរិបទនៃព្រះបន្ទូលសន្យាទាំងនោះ ។

## និមិត្តរូបនៃព្រះគម្ពីរ

និមិត្តរូបប្រាំពីរដែលបានយកមកប្រើ ដើម្បីបង្ហាញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើនិមិត្តរូបទាំងនោះមានអ្វីខ្លះ?

១ ហេព្រើរ ៤:១២ ________________
២. យេរេមា ២៣:២៩ ________________
៣ យេរេមា ២០:៩ ________________
៤. ១ពេត្រុស ១:២៣ ________________
៥. ១ពេត្រុស ២:២ ________________
៦. យ៉ាកុប ១:២៣-២៤________________
៧. ទំនុកដំកើង ១១៩:១០៥ ________________

## ហេតុផលនៃការទទួលស្គាល់ព្រះគម្ពីរ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

### ១. ទីបន្ទាល់របស់ព្រះអម្ចាស់ផ្ទាល់

ទ្រង់បានបង្ហាញពីជំនឿដ៏ឥតរង្គើរ នៅក្នុងឧប្បត្តិហេតុនៃគម្ពីរសញ្ញាចាស់។

| | |
|---|---|
| ព្រះយេស៊ូបានលើកឡើងពីៈ | |
| ការបង្កើតពិភពលោក | ម៉ាថាយ ១៩:៤ |
| លោកណូអេ និងទឹកជំនន់ | លូកា ១៧: ២៦-២៧ |
| ដណ្ដើររបស់យ៉ាកុប | យ៉ូហាន ១:៥១ |

### ២. ព្រះគម្ពីរផ្ទាល់ ជាអ្នកប្រកាសថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

សូមអាន កិច្ចការ ១:១៦, ២ធីម៉ូថេ ៣:១៦-១៧

បទគម្ពីរជាច្រើនបង្ហាញថា អ្នកសរសេរព្រះគម្ពីរ ពួកគាត់សុទ្ធតែជឿថាពួកគាត់មានការបណ្ដាលមកពីព្រះ។

### ៣. ភាពស្របគ្នារបស់ព្រះគម្ពីរ

ព្រះគម្ពីរជាបណ្ណាល័យសៀវភៅ៦០កណ្ឌ ដែលសរសេរឡើងដោយអ្នកនិពន្ធជាង៤០នាក់។ អ្នកនិពន្ធភាគច្រើនរស់នៅឆ្ងាយពីគ្នា និងស្ថិតនៅក្រោមស្ថានភាពជីវិតខុសៗគ្នា ប៉ុន្តែមានផ្ទៃរឿងតែមួយ និងស្របគ្នាគ្រប់ទាំងកណ្ឌគម្ពីរទាំងអស់។ ក៏មានទស្សនៈដូចគ្នាពីមូលដ្ឋានគ្រឹះ នៃគោលលទ្ធិរបស់ ព្រះជាម្ចាស់ មនុស្ស និងអំពើបាប នេះគ្រាន់តែជាការលើកឡើងនូវឈ្មោះពីរបីតែប៉ុណ្ណោះ។

### ៤. ព្រះគម្ពីរនៅតែមានចម្លើយសម្រាប់មនុស្សទាំងអស់ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ឬ សម័យកាលណានោះទេ

ខាងក្រោមនេះជាកិច្ចការមួយចំនួនដែលព្រះគម្ពីរនឹងធ្វើការទៅតាមស្ថានភាពដែលមនុស្សកំពុងប្រឈមនាពេលបច្ចុប្បន្ន។

សូមបំពេញចន្លោះ ចេញពីខគម្ពីរដែលមាននៅខាងក្រោមនេះ ៖

សូមនាំឱ្យទូលបង្គំមានជីវិតខាងវិញ្ញាណ ________________

សូមពិនិត្យមើលគំនិត និងបំណងចិត្តរបស់ទូលបង្គំ ____________

សូមសម្អាត និងវិសុទ្ធទូលបង្គំ ____________

ផ្តល់ជំនឿ ____________

ផ្តល់ក្តីអំណរ ____________

ប្រាប់ខ្ញុំនូវអ្វីដែលត្រូវអធិស្ឋាន

____________

ផ្តល់ការណែនាំ ____________

ផ្តល់សុវត្ថិភាព ____________

បង្កើតឲ្យមានផលផ្លែ

____________

ផ្តល់ប្រាជ្ញា ____________

ផ្តល់ការធានាថាទូលបង្គំជាកូនរបស់ព្រះជាម្ចាស់ ____________

ទំនុកដំកើង ១:១-៣; ទំនុកដំកើង ១៩:៨; ទំនុកដំកើង១១៩:១១; យ៉ូហាន ១:១២; ទំនុកដំកើង ១១៩:១០៥; ទំនុកដំកើង ១១៩:១៥៦; យ៉ូហាន ៦:៦៣; រ៉ូម ១០:១៧; ១ កូរិនថូស ២:៦-៧; ហេព្រើរ ៤:១២; ១ យ៉ូហាន ៥:១៤-១៥ ។

## សេចក្តីសន្និដ្ឋាន

នៅពេលយើងអានព្រះគម្ពីរ ត្រូវមានឥរិយាបថនៃការរំពឹងទុក។ ត្រូវជឿថា ព្រះជាម្ចាស់ដ៏មានមហិទ្ធិឫទ្ធិទ្រង់សព្វព្រះហរទ័យមានព្រះបន្ទូលមកកាន់លោកអ្នក។ មិនត្រូវមានភាពខ្ជិលច្រអូសនៅក្នុងការអានព្រះគម្ពីរនោះឡើយ



ដោយគ្រាន់តែបើកព្រះគម្ពីររួចរកកន្លែងដែលត្រូវអានប៉ុណ្ណោះ ។ គួរតែចាប់ផ្តើមអានពីដើមនៃកណ្ឌគម្ពីរមួយ (ឧទាហរណ៍៖ ដំណឹងល្អយ៉ូហាន) ហើយអានរហូតដល់ចប់ព្រោះវានឹងជួយឲ្យយើងយល់ពីផ្ទៃរឿងទាំងមូលនៃកណ្ឌគម្ពីរនីមួយៗ។

មានជំនួយផ្សេងទៀត ដូចជាការព្រីនចេញនូវកំណត់ត្រាសម្រាប់អានប្រចាំថ្ងៃដែលមានស្រាប់ក៏អាចជួយដល់ការយល់ពីអត្ថន័យនៃបទគម្ពីរ។ ការបកប្រែព្រះគម្ពីរមួយចំនួនក៏អាចទាញយកមកប្រើបាននៅលើអាយផត (Ipod) របស់លោកអ្នកបានដែរ 'បទពិសោធន៍ព្រះគម្ពីរ' ដែលមាននៅតាម **CD** ឬ**MP3** ដែលមានការថតចម្លងបានយ៉ាងល្អ។ កម្រងអត្ថាធិប្បាយដែលមានប្រយោជន៍ តែត្រូវប្រាកដថាគ្មានសៀវភៅណាដែលអាចយកមកជំនួសព្រះគម្ពីរបាននោះឡើយ។ សៀវភៅជំនួយទាំងនេះអាចរកទិញបាននៅតាមបណ្ណាគារគ្រិស្តបរិស័ទមួយចំនួន។

ជាការសំខាន់នៅក្នុងការចងចាំព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ឧទាហរណ៍៖ បើមានខគម្ពីរណាមួយដែលមានអត្ថន័យពិសេសចំៗ នោះចូរសរសេរខគម្ពីរនោះនៅលើកាតមួយ ដោយធ្វើការពិចារណាខគម្ពីរនោះនៅក្នុងថ្ងៃនោះឯង។ ក៏ជាប្រយោជន៍ផងដែរ ក្នុងមួយសប្តាហ៍ម្តងបើមាននរណាម្នាក់អាចត្រួតពិនិត្យ មើលលោកអ្នក និងស្តាប់លោកអ្នកទន្ទេញខគម្ពីរ។

សូមអាន ហើយស្វែងរកកំណប់ទ្រព្យមហាសាលដែលមាននៅក្នុងព្រះបន្ទូលដ៏មានតម្លៃរបស់ព្រះជាម្ចាស់ចុះ។